# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាប្រជុំប្រធាននិងអនុប្រធានក្រុមយុវជនភូមិភាគភ្នំពេញនៅព្រែកប្បាស់
# ថ្ងៃទី២១ ឧសភា ២០១៧

អត្ថបទទី១៖ កក ២,៥-៨.១៤-១៧
អត្ថបទទី២៖ សល ៣,១៥-១៨
ដំណឹងល្អ៖ យហ ១៤,១៥-២១

បងប្អូនជាទីស្រឡាញ់!

បើយើងចាប់អារម្មណ៍អំពីអត្ថបទទាំងបី ដែលយើងបានស្តាប់ថ្ងៃនេះ យើងមានពាក្យព្រះវិញ្ញាណដ៏វិសុទ្ធច្រើនដង ទាំងក្នុងអត្ថបទីទីមួយ ទាំងអត្ថបទទីពីរ និងអត្ថបទគម្ពីរដំណឹងល្អ។ នៅក្នុងព្រះគម្ពីរដំណឹងល្អ ព្រះយេស៊ូមានព្រះបន្ទូលថា **"យើងផ្ញើព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាព្រះដ៏ជួយការពារមួយអង្គទៀត"**។ នៅពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក លោកអភិបាល ឬលោកបូជាចារ្យ បាននិយាយថា ខ្ញុំធ្វើពិធីជ្រមុជទឹកដោយនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ពេលយើងជាគ្រិស្តបរិស័ទ យើងអាចនិយាយថាយើងជាប្រជាជនរបស់ព្រះជាម្ចាស់ ដែលបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធជាវិញ្ញាណរបស់ព្រះជាម្ចាស់ដែលបំភ្លឺយើង ដែលផ្តល់កម្លាំងឲ្យយើង ការពារថែរក្សាយើង ដែលណែនាំឲ្យយើងមានសេចក្តីស្រឡាញ់រវាងគ្នានឹងគ្នា។ ថ្ងៃនេះយើងស្តាប់ពាក្យមួយដ៏សំខាន់នៅក្នុងអត្ថបទទីពីរ **"ត្រូវប្រុងប្រៀបខ្លួន ឆ្លើយតទល់នឹងអស់អ្នកដែលសាកសួរអំពីសេចក្តីសង្ឃឹមរបស់បងប្អូនជានិច្ច"** សម្រាប់យើងជាគ្រិសបរិស័ទ ដែលបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ យើងត្រូវប្រុងប្រៀបខ្លួនដើម្បីឆ្លើយតទល់នឹងបងប្អូនទាំងអស់ ដើម្បីផ្តល់សក្ខីភាពអំពីសេចក្តីសង្ឃឹមដែលយើងមាន។

យើងជាព្រះសហគមន៍មួយយ៉ាងតូច ក្នុងចំណោមបងប្អូនពុទ្ធបរិស័ទជាច្រើន យើងត្រូវឆ្លើយតបអំពីសេចក្តីសង្ឃឹមរបស់យើង យើងត្រូវការបង្ហាញអំពីសេចក្តីសង្ឃឹមរបស់យើង។ សេចក្តីសង្ឃឹមរបស់យើង គឺជាសក្ខីភាពដែលយើងផ្តល់ ដូចនៅក្នុងអត្ថបទទីមួយ មានមនុស្សច្រើនដែលបានទទួលពិធីជ្រមុជទឹក ដែលចង់ដើរតាមព្រះយេស៊ូដោយសារគេឃើញផ្ទាល់ភ្នែក **"យើងបានឃើញទីសម្គាល់ដ៏អស្ចារ្យដែលលោកបានធ្វើ ទីមួយមានខ្មោចយ៉ាងច្រើនចេញពីមនុស្សទាំងស្រែកខ្លាំងៗ ទីពីរមានមនុស្សខ្វិន មនុស្សស្លាប់ដៃជើងជាច្រើនដែលបានជាសាស្បើយ"** គេបានឃើញសញ្ញាជាសក្ខីភាពមួយយ៉ាងពិសេស។ សម្រាប់យើងដើម្បីផ្តល់និងពន្យល់អំពីសេចក្តីសង្ឃឹមរបស់យើង យើងត្រូវការបង្ហាញសក្ខីភាពយ៉ាងច្បា

ស់។ សម្រាប់យុវជនត្រូវការគិត **តើក្រុមយុវជនរបស់យើងត្រូវការផ្តល់សក្ខីភាពអ្វីខ្លះសម្រាប់បងប្អូនឯទៀតៗអាចយល់ឃើញពីសេចក្តីសង្ឃឹមរបស់យើង?** សក្ខីជាអ្វីដែលសំខាន់បំផុតដោយមិនជាការបង្ហាញអាគារ បង្ហាញកន្លែង ប៉ុន្តែសក្ខីភាពជាសកម្មភាពនៃជីវិតប្រចាំថ្ងៃរបស់យើង។ ជាក់ស្តែង សប្តាហ៍មុនខ្ញុំបានទទួលលោកអភិបាលមកពី ម៉ាឡេស៊ី ដើម្បីណែនាំសំណាក់ធមិបូជាចារ្យទាំងអស់នៅកម្ពុជា ខ្ញុំបានបង្ហាញកន្លែងខ្លះៗដែលយើងមាននៅខេត្តតាកែវ។ ប៉ុន្តែជាថ្ងៃឈប់សម្រាក គឺយើងមានតែអាគារគ្មានសកម្មភាពអ្វីទាំងអស់នៅពេលគាត់ណែនាំសំណាក់លោកបូជាចារ្យ ឥតនិយាយមួយម៉ាត់អំពីអ្វីដែលគាត់បានឃើញនៅតាកែវ ដោយសារគាត់មិនចាប់អារម្មណ៍ព្រោះគាត់ឃើញតែអាគារដែលគ្មានមនុស្ស។ យើងអាចផ្តល់សក្ខីភាពនៅពេលយើងជួបជាមួយយើងផ្ទាល់ ពេលយើងចង់បង្ហាញអំពីសេចក្តីសង្ឃឹមរបស់យើង ឲ្យយើងបង្ហាញជាក់ស្តែងថាព្រះសហគមន៍យើងជាជាគ្រួសារមួយដែលចេះស្រឡាញ់គ្នាទៅវិញទៅមក។ ដូចនៅសន្តប៉ូលសព្វថ្ងៃគ្រូអប់រំជំនឿថាមានលោកតាលោកយាយជាង៥០នាក់បានចូលដើម្បីទទួលការអប់រំ។ នេះដោយសារគាត់ឃើញមានលោកតាលោកយាយប៉ុន្មាននាក់ បានទទួលពិធីជ្រមុជទឹក មានសេចក្តីសុខមានអំណរសប្បាយ ជាគ្រួសារមួយដែលចេះលើកទឹកចិត្តគ្នា ចេះជួយគ្នា ជាគ្រួសារកក់ក្តៅមិនមែនដោយសារគេលឺ គេឃើញ គេថា គឺគេឃើញផ្ទាល់ភ្នែក។

សម្រាប់យើងដែលជាយុវជន ពេលយើងគិតអំពីសកម្មភាពដែលយើងត្រូវធ្វើជារៀងរាល់ខែ យើងអាចប្រជុំគ្នាបានដើម្បីគិតអំពីព្រះគម្ពីរដំណឹងល្អ ដើម្បីគិតអំពីជីវិតយើង។ ប៉ុន្តែសំខាន់ឲ្យយើងចេញពីព្រះវិហាររបស់យើង ដើម្បីមានស្នាដៃខ្លះៗ ដូចជានាំក្មេងកាយឫទ្ធិទៅសួរសុខទុក្ខអ្នកជំងឺ អ្នកតូចតាច អ្នកក្រីក្រ ចាស់ជរា នេះជាស្នាដៃមួយដែលណែនាំឲ្យបងប្អូនយល់អំពីសេចក្តីសង្ឃឹមរបស់យើង។ មួយខែម្តងឲ្យយើងមានស្នាដៃមួយ ដែលបង្ហាញអំពីសេចក្តីស្រឡាញ់ចំពោះអ្នកដែលគ្មានទីពឹង គ្មានសេចក្តីសង្ឃឹម នេះណែនាំឲ្យព្រះសហគមន៍របស់យើងអាចផ្តល់សក្ខីភាពពិតមែន អំពីសេចក្តីសង្ឃឹមដោយសារគេមើលជាក់ស្តែងពីជីវិតរបស់យើង។ យើងអាចនិយាយថា យើងកសាងព្រះសហគមន៍នៅក្នុងព្រះវិញ្ញាណ ដោយដើរតាមព្រះយេស៊ូ ដោយផ្តល់សក្ខីភាពអំពីព្រះយេស៊ូ គឺរបៀបដែលព្រះអង្គណែនាំឲ្យយើងរស់នៅក្នុងធម្មវិន័យរបស់ព្រះយេស៊ូ។ ស្រឡាញ់គ្នាទៅវិញទៅមក បង្កើតគ្រួសារមួយដែលចេះជួយគ្នាទៅវិញទៅមក ដើម្បីចែករំលែកអំពីអំណរសប្បាយនៃដំណឹង

ល្អ និងអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ អស់មួយជីវិតរបស់យើង យើងត្រូវមានសកម្មភាពខ្លះៗដើម្បីបង្ហាញអំពីមេត្តាករុណា ដើម្បីណែនាំឲ្យបងប្អូនទាំងអស់យល់ថាព្រះបិតាស្រឡាញ់យើង ការពារយើង និងលើកទឹកចិត្តយើងជានិច្ចដើម្បីឲ្យយើងរស់នៅក្នុងសេចក្ដីសង្ឃឹម។

ថ្ងៃនេះយើងអធិដ្ឋាន ដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ដើម្បីឲ្យយើងផ្ដល់សក្ខីភាពអំពីសេចក្ដីស្រឡាញ់ តាមរបៀបសាមញ្ញងាយស្រួល ប៉ុន្តែជារបៀបមួយដែលបានណែនាំឲ្យបងប្អូនជាច្រើនអាចភ្ញាក់ស្មារតី និងយល់ថាពិតមែនព្រះជាម្ចាស់ជាជីវិត ពិតមែនព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់។ ថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ និងយើងគិតពិចារណាម្ដងទៀតអំពីសក្ខីភាពដែលយើងផ្ដល់ជាក់ស្ដែង ឲ្យគេឃើញសញ្ញាសម្គាល់ជាក់ស្ដែង។ អាម៉ែន។